**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងការបរទេស**
**និងសហប្រតិបត្តិការអន្តរជាតិ**

# សេចក្តីប្រកាសព័ត៌មាន
## ពិធីប្រគល់តំណែងប្រធានអាស៊ាន ឆ្នាំ២០២២ ជូនព្រះរាជាណាចក្រកម្ពុជា នៅថ្ងៃទី២៨ ខែតុលា ឆ្នាំ២០២១ តាមប្រព័ន្ធវីដេអូ

នៅរសៀលថ្ងៃទី ២៨ ខែតុលា ឆ្នាំ២០២១ នៅក្នុងពិធីបិទជាផ្លូវការនៃកិច្ចប្រជុំកំពូលអាស៊ានលើកទី ៣៨ និង៣៩ និងកិច្ចប្រជុំកំពូលពាក់ព័ន្ធ **ព្រះចៅស៊ុលតង់ ហាជី ហាសសាណាល់ បុលគីយ៉ាស** ព្រះមហាក្សត្រ នៃប្រទេសព្រុយណេដារូស្សាឡាម បានសម្តែងនូវការកោតសរសើរដល់គ្រប់ប្រទេសជាសមាជិកអាស៊ាន និងដៃគូសន្ទនាទាំងអស់ ដែលបានគាំទ្រចំពោះការធ្វើជាប្រធានអាស៊ានរបស់ប្រទេសព្រុយណេ ឱ្យសម្រេចបាននូវសមិទ្ធិផលសំខាន់ៗ និងអាទិភាពផ្សេងៗ ក្នុងឆ្នាំដែលតំបន់ខិតខំប្រឹងប្រែងកសាងសហគមន៍អាស៊ានដោយផ្តោតជាសំខាន់ទៅលើប្រជាជន ក្រោមមូលបទ »**យើងយកចិត្តទុកដាក់ យើងត្រៀមលក្ខណៈ យើងរីកចំរើន**«។ ព្រះចៅស៊ុលតង់ ព្រះមហាក្សត្រ នៃព្រុយណេដារូស្សាឡាម បានប្រគល់ញញួរប្រធានអាស៊ានជូន **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា និងបានជូនពរជ័យដល់ព្រះរាជាណាចក្រកម្ពុជា ឱ្យទទួលបានជោគជ័យគ្រចះគ្រចង់ក្នុងការកាច់ចង្កូតកិច្ចខិតខំប្រឹងប្រែងកសាងសហគមន៍អាស៊ាន ឆ្នាំ២០២២។

**សម្តេចតេជោនាយករដ្ឋមន្ត្រី** បានកោតសរសើរ **ព្រះចៅស៊ុលតង់ ហាជី ហាសសាណាល់ បុលគីយ៉ាស** សម្រាប់ភាពជាអ្នកដឹកនាំប្រកបដោយគតិបណ្ឌិត និងប្រសិទ្ធភាព ក្នុងការកាច់ចង្កូតនាវាអាស៊ានឆ្ពោះទៅសម្រេចបានលទ្ធផលប្រកបដោយផ្លែផ្កា។ **សម្តេចតេជោនាយករដ្ឋមន្ត្រី** បានប្រកាសមូលបទប្រធានអាស៊ាន ឆ្នាំ២០២២ របស់កម្ពុជា «**អាស៊ានរួមគ្នាធ្វើ៖ ដោះស្រាយបញ្ហាប្រឈមទាំងអស់គ្នា**» សម្រាប់សុខដុមរមនា សន្តិភាព និងវិបុលភាពនៅក្នុងតំបន់ទាំងមូល។ មូលបទបានគូសបញ្ជាក់នូវស្មារតីរបស់អាស៊ាន «ទាំងអស់រួមគ្នា» ជាសហគមន៍តែមួយជាមួយឆន្ទៈរួម ដើម្បីជម្នះការប្រឈមនានាដែលកំពុងមានក្នុងតំបន់ តាមរយៈវិធីសាស្ត្រផ្តោតសំខាន់លើសកម្មភាពដែល ផ្អែកលើភាពបើកចំហ សុចរិតភាព សាមគ្គីភាព និងការគោរពគ្នាទៅវិញទៅមកដោយស្មើភាពគ្នា។

ក្រោមមូលបទនេះ **សម្តេចតេជោនាយករដ្ឋមន្ត្រី** អះអាងអំពីការប្តេជ្ញាចិត្តរបស់កម្ពុជា ក្នុងការដឹកនាំកិច្ចខិតខំប្រឹងប្រែងរួមរបស់អាស៊ាន ដើម្បីសម្រេចបានកិច្ចការសំខាន់ៗ ជាពិសេស ការពន្លឿនដំណើរការកសាងសហគមន៍អាស៊ានមួយដែលមានសមធម៌ រឹងមាំ និងប្រកបដោយបរិយាប័ន្ន ស្របតាមស្មារតីស្នូលរបស់អាស៊ាន៖ «ទស្សនវិស័យមួយ អត្តសញ្ញាណមួយ សហគមន៍មួយ»។



អាសយដ្ឋាន: លេខ ៣ វិថី សម្តេច ហ៊ុន សែន
សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ : (855) 23 216 122
ទូរសារ : (855) 23 216 141, 023 213 341
អ៊ីម៉ែល : mfaic@mfaic.gov.kh

សម្តេចតេជោនាយករដ្ឋមន្ត្រី បានធ្វើបទបង្ហាញអំពីអាទិភាពសំខាន់ៗរបស់កម្ពុជា នៅឆ្នាំ២០២២ ដែលរួមមាន៖

- សម្រាប់សសរស្តម្ភនយោបាយ និងសន្តិសុខ៖ កម្ពុជា នឹងផ្តោតការយកចិត្តទុកដាក់លើការពង្រឹងមជ្ឈភាពអាស៊ាន និងឯកភាពអាស៊ាន ទាំងនៅក្នុងយន្តការតំបន់ និងកិច្ចសហប្រតិបត្តិការជាមួយដៃគូខាងក្រៅ ដោយឈរលើ «មាគ៌ា និងគោលការណ៍អាស៊ាន» ដូចមានចែងក្នុងធម្មនុញ្ញអាស៊ាន (ASEAN Charter) សន្ធិសញ្ញាមិត្តភាពនិងកិច្ចសហប្រតិបត្តិការនៅអាស៊ីអាគ្នេយ៍ (TAC) និងទស្សនវិស័យអាស៊ានស្តីពីឥណ្ឌូ-ប៉ាស៊ីហ្វិក (AOIP)។ អាស៊ានត្រូវតែមានភាពធន់ និងរឹងមាំ ប្រឆាំងនឹងសម្ពាធ និងឥទ្ធិពល ដែលបណ្តាលមកពីការកើនឡើងនៃការប្រកួតប្រជែងភូមិសាស្ត្រ-នយោបាយ ឧក្រិដ្ឋកម្មឆ្លងដែន អំពើភេរវកម្ម ការប្រែប្រួលអាកាសធាតុ និងជំងឺឆ្លងរាតត្បាត ជាដើម ដើម្បីធានាថា មាគ៌ាឆ្ពោះទៅមុខប្រកបដោយសន្តិភាព សន្តិសុខ និងវិបុលភាព។
- សម្រាប់សសរស្តម្ភសេដ្ឋកិច្ច៖ កម្ពុជា នឹងជំរុញការអនុវត្តប្រកបដោយប្រសិទ្ធភាពនូវរាល់គំនិតផ្តួចផ្តើម និងវិធានការផ្សេងៗដែលបានឯកភាពគ្នា ក៏ដូចជា ទាញយកផលប្រយោជន៍ពីកិច្ចព្រមព្រៀងពាណិជ្ជកម្មនានាឱ្យបានជាអតិបរមា ដើម្បីពន្លឿនការងើបឡើងវិញនៃកំណើនសេដ្ឋកិច្ច ខណៈពេលដែលយើងកំពុងរស់នៅជាមួយជំងឺកូវីដ-១៩ ក្នុងសភាពធម្មតាតាមបែបគន្លងថ្មី និងធានាឱ្យបានថា អាស៊ាននៅតែជាមជ្ឈមណ្ឌលដ៏ទាក់ទាញ និងប្រកបដោយថាមវន្ត សម្រាប់ពាណិជ្ជកម្ម និងវិនិយោគ តាមរយៈការលើកកម្ពស់ការតភ្ជាប់ទាំងផ្នែករូបវន្ត និងឌីជីថល ការពង្រឹងសមត្ថភាពសហគ្រាសខ្នាតមីក្រូ តូច និងមធ្យម និងការលើកកម្ពស់សហគ្រិនភាពក្នុងចំណោមស្ត្រី និងយុវជន ក៏ដូចជា អាទិភាពផ្សេងទៀតក្នុងគោលបំណងបង្រួមគម្លាតអភិវឌ្ឍន៍ និងជំរុញសមាហរណកម្មតំបន់។
- សម្រាប់សសរស្តម្ភសង្គម-វប្បធម៌៖ កម្ពុជា នឹងពង្រឹងការអភិវឌ្ឍធនធានមនុស្ស ដើម្បីឆ្លើយតបទៅនឹងតម្រូវការជាក់ស្តែងសម្រាប់ការកសាងសហគមន៍ លើកកម្ពស់ការចូលរួមរបស់ស្ត្រី និងយុវជននៅក្នុងការកសាង និងថែរក្សាសន្តិភាព ព្រមទាំងអភិវឌ្ឍប្រព័ន្ធគាំពារសង្គមមួយប្រកបដោយបរិយាប័ន្ន។ ចំនុចអាទិភាពសំខាន់មួយទៀតនោះគឺ ការពង្រឹងចំណងទាក់ទងរវាងប្រជាជន និងប្រជាជន ដើម្បីពង្រឹងស្មារតី «អត្តសញ្ញាណអាស៊ានតែមួយ»។

ជាចុងបញ្ចប់ សម្តេចតេជោនាយករដ្ឋមន្ត្រី បានទទួលរង់ចាំដល់ការស្វាគមន៍យ៉ាងកក់ក្តៅចំពោះគណៈប្រតិភូទាំងអស់អញ្ជើញមកកាន់ព្រះរាជាណាចក្រកម្ពុជា នៅឆ្នាំ២០២២៕

ថ្ងៃព្រហស្បតិ៍ ៧រោច ខែអស្សុជ ឆ្នាំឆ្លូវ ត្រីស័ក ព.ស. ២៥៦៥
រាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែតុលា ឆ្នាំ២០២១